**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

Ministry of Labour and Vocational Training

**ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ**

លេខ : ០២៤/២៤ ក.ប/ស.ជ.ល.ព.ប

# សេចក្តីជូនដំណឹង

## ស្តីពី

## នីតិវិធីនៃការបញ្ជូន និងដំណើរការឯកសារពលករកម្ពុជាទៅធ្វើការនៅបរទេស

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់សាធារណជន ជាពិសេសប្រជាពលរដ្ឋកម្ពុជាដែលមានបំណងទៅធ្វើការនៅបរទេសឱ្យបានជ្រាបថា ដើម្បីស្នាក់នៅ និងធ្វើការនៅបរទេសដោយស្របច្បាប់ បងប្អូនត្រូវមានឯកសារសំខាន់ៗដូចជា កិច្ចសន្យាសេវារកការងារឱ្យធ្វើ កិច្ចសន្យាការងារ ប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស (OCWC) លិខិតឆ្លងដែន/លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស (TD) ទិដ្ឋាការការងារ និងប័ណ្ណអនុញ្ញាតការងារ។ ក្នុងន័យនេះ ដើម្បីសាធារណជន ជាពិសេសប្រជាពលរដ្ឋកម្ពុជាដែលមានបំណងទៅធ្វើការនៅបរទេស អាចយល់ដឹងអំពីនីតិវិធីបញ្ជូន និងដំណើរការឯកសារពលករកម្ពុជាទៅធ្វើការនៅបរទេស ក្រសួងសូមផ្តល់លំហូរនៃនីតិវិធីទៅធ្វើការនៅប្រទេសថៃ សាធារណរដ្ឋកូរ៉េ ប្រទេសជប៉ុន ប្រទេសសិង្ហបុរី និងតំបន់រដ្ឋបាលពិសេសហុងកុង ដូចមានឯកសារជូនភ្ជាប់មកជាមួយ។

ទន្ទឹមនឹងនេះ សាមីពលករកម្ពុជា អាចតាមដានដំណើរការឯកសាររបស់ខ្លួនតាមដំណាក់កាលនីមួយៗ ចាប់ពីដំណាក់កាលចុះឈ្មោះស្វែងរកការងារ រហូតដល់ចប់កិច្ចសន្យាការងារ និងវិលត្រឡប់មកកម្ពុជាវិញ តាមរយៈគេហទំព័រ https://tracking.ocwc.co/។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈប្រព័ន្ធ Hotline លេខ ១២៩៧ ឬ ១២៨៦ ឬក្រុមតេលេក្រាម "សម្រាប់ ពលករទេសន្តរប្រវេសន៍" https://t.me/KhmerMigrantWorker និងទំនាក់ទំនងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈទាំង២៥ រាជធានី ខេត្ត នៅរៀងរាល់ម៉ោងធ្វើការ ឬពិនិត្យមើលបញ្ជីឈ្មោះទីភ្នាក់ងារជ្រើសរើសឯកជន ដែលមាននៅក្នុងគេហទំព័ររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ https://www.mlvt.gov.kh/។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន ជាពិសេសប្រជាពលរដ្ឋកម្ពុជាដែលមានបំណងទៅធ្វើការនៅបរទេស មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃព្រហស្បតិ៍ ១៥ កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៤

**រដ្ឋមន្ត្រី**

**ហេង សួរ**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាពក្រោមឱវាទក្រសួង
- សមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា
- ឯកសារ កាលប្បវត្តិ

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨៤ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

# នីតិវិធី ទៅធ្វើការនៅប្រទេសកូរ៉េ ដោយស្របច្បាប់

ដើម្បីទៅធ្វើការនៅប្រទេសកូរ៉េដោយស្របច្បាប់ក្រោមប្រព័ន្ធអនុញ្ញាតមុខរបរ (EPS)៖

## 1 ការប្រឡងតេស្តសមត្ថភាព

ដើម្បីក្លាយជាបេក្ខជនប្រឡងជាប់ជាស្ថាពរ បេក្ខជនត្រូវឆ្លងកាត់ការប្រឡងតេស្តសមត្ថភាព ២ដំណាក់កាល៖

- ការប្រឡងតេស្តសមត្ថភាពភាសាកូរ៉េតាមប្រព័ន្ធកុំព្យូទ័រមានរយៈពេល ៥០នាទី ចែកចេញជា ២វិញ្ញាសាគឺ វិញ្ញាសាអាន ២៥នាទី និងវិញ្ញាសាស្តាប់ ២៥នាទី។ វិញ្ញាសាប្រឡង និងកំណែវិញ្ញាសាត្រូវបានចងក្រងផលិតដោយ HRD-Korea តាមរយៈប្រព័ន្ធកុំព្យូទ័រ។
- ប្រឡងតេស្តជំនាញ និងវាយតម្លៃសមត្ថភាព គឺធ្វើឡើងបន្ទាប់ពីការប្រឡងជាប់តេស្តសមត្ថភាពភាសាកូរ៉េ ការប្រឡងមាន ៣វិញ្ញាសាដូចជា តេស្តជំនាញមូលដ្ឋាន តេស្តកាយសម្បទា និងសម្ភាសជាភាសាកូរ៉េ។

## 2 ការដាក់ពាក្យស្វែងរកការងារតាមប្រព័ន្ធ SPAS

សុពលភាពនៃការដាក់ពាក្យស្វែងរកការងារមានរយៈពេល ២ឆ្នាំ គិតពីលទ្ធផលជាប់ជាស្ថាពរបេក្ខជនអាចតាមដានដំណើរការអន្តោប្រវេសន៍តាមរយៈគេហទំព័ររបស់ HRD-Korea (www.eops.og.kr) ក្រោយដាក់ពាក្យរយៈពេល៣០ថ្ងៃ។ បេក្ខជនត្រូវភ្ជាប់មកជាមួយ ៖

- ពាក្យសុំស្វែងរកការងារធ្វើ
- វិញ្ញាបនបត្រពិនិត្យសុខភាព (ពេទ្យការងារ)
- លិខិតឆ្លងដែនច្បាប់ដើម
- សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតច្បាប់ដើម
- សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅថតចម្លង
- លេខគណនីធនាគារផ្ទាល់ខ្លួននៅកម្ពុជា
- អត្តសញ្ញាណប័ណ្ណច្បាប់ដើម
- បង្កាន់ដៃសុំសិទ្ធិប្រឡង
- រូបថត ៣.៥x៤.៥ ៤សន្លឹក (ផ្ទៃខាងក្រោយពណ៌ស)
- ឆ្លងកាត់ស្កេនក្រយៅដៃ

## 3 ការទទួលកិច្ចសន្យាការងារពីនិយោជកកូរ៉េ

និយោជកកូរ៉េជ្រើសរើសពលករបរទេសតាមប្រព័ន្ធកុំព្យូទ័រមិនអាចបញ្ជាក់ចំណោះពលករណាមួយឡើយ ការជ្រើសរើសធ្វើឡើងដោយតម្លាភាពពុំមានបុគ្គល ឬអង្គភាពណាមួយជួយឱ្យធ្លាក់ឈ្មោះបានឡើយ។ និយោជកកូរ៉េជ្រើសរើសពលករួច (ចេញជូន) ប៉ុន្តែនិយោជកកូរ៉េមិនបានរៀបចំឯកសារគ្រប់គ្រាន់ ឈ្មោះនឹងត្រូវដាក់ចូលក្នុងបញ្ជីស្វែងរកការងារធ្វើឡើងវិញ។ ពលករត្រូវមកចុះកិច្ចសន្យាការងារក្នុងរយៈពេល ០១សប្តាហ៍គិតចាប់ពីថ្ងៃទទួលបានការជូនដំណឹងស្តីពីកិច្ចសន្យាការងារពី គ.ប.ប.ព.ប។

ពេលមកពិនិត្យលក្ខណការងារ និងចុះកិច្ចសន្យាបេក្ខជនត្រូវភ្ជាប់មកជាមួយនូវ៖

- លិខិតឆ្លងដែនច្បាប់ដើម និងថតចម្លងពណ៌ធម្មជាតិ ០៨ច្បាប់
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតច្បាប់ដើម
- សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅថតចម្លង
- រូបថត ៣.៥x៤.៥ ស.ម (ផ្ទៃខាងក្រោយពណ៌ស)

## 4 ការចេញដំណើរ

ក្រោយចុះកិច្ចសន្យា និងរៀបចំឯកសាររយៈពេល ៤៥ថ្ងៃទៅ ៦០ថ្ងៃ គ.ប.ប.ព.ប សហការជាមួយ HRD-Korea នឹងរៀបចំសម្របសម្រួលការចេញដំណើររបស់ពលករ។ បេក្ខជនត្រូវភ្ជាប់មកជាមួយនៅ ៖

- វិញ្ញាបនបត្របញ្ចប់វគ្គបណ្តុះបណ្តាល
- ព្រឹត្តិបត្រថ្កោលទោស
- ទិដ្ឋាការ (E-9) ពីស្ថានទូតកូរ៉េ
- វិញ្ញាបនបត្រពិនិត្យសុខភាព
- គណនីធនាគារផ្ទាល់ខ្លួន (ថតចម្លង)

## 5 ការគាំពារ និងការធ្វើមាតុភូមិនិវត្តន៍

- ទទួលលិខិតបញ្ជាក់ការងារពីនិយោជក
- ទូទាត់ប្រាក់សោធននិវត្តន៍ និងអត្ថប្រយោជន៍ផ្សេងៗ
- ពលករវិលត្រឡប់មកប្រទេសកម្ពុជាវិញ ត្រូវរាយការណ៍អំពីការវិលត្រឡប់ មកក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ


ករណីមានចម្ងល់ សូមទំនាក់ទំនងប្រព័ន្ធ
ទូរស័ព្ទលេខ 011 383 735 ឬ 012 466 222

https://www.facebook.com/mtosbcambodia

https://t.me/epscambodia

ស្ថានឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសកូរ៉េ

អនុព័ន្ធការងារអមស្ថានទូតកម្ពុជាប្រចាំប្រទេសកូរ៉េ - Labour Attaché

+82-10-5129-1975

# នីតិវិធី ទៅធ្វើការនៅប្រទេសសិង្ហបុរី ដោយស្របច្បាប់

ដើម្បីទៅធ្វើការងារ នៅប្រទេសសិង្ហបុរីដោយស្របច្បាប់ ពលករត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

## 1 ការចុះឈ្មោះស្វែងរកការងារ ( ១ ថ្ងៃ )

- អាយុចាប់ពី ២៣ ឆ្នាំ ដល់ ៥០ ឆ្នាំ
- ភេទស្រី
- ត្រូវមានកម្រិតវប្បធម៌ទូទៅចាប់ពីថ្នាក់ទី៨ ឡើងទៅ
- ប្រវត្តិរូបសង្ខេប
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- សំបុត្រកំណើត
- សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ
- រូបថត ៤ x ៦ (ផ្ទៃស)

## 2 ការសម្ភាស និងចុះកិច្ចសន្យា ( ១ ថ្ងៃ )

- សម្ភាសជាមួយនិយោជកសិង្ហបុរី
- ចុះកិច្ចសន្យាសេវារកការងារឱ្យធ្វើ ជាមួយទីភ្នាក់ងារជ្រើសរើសឯកជន

## 3 មុនពេលចេញដំណើរ ( ៩ ថ្ងៃ )

- ទទួលបានការបណ្តុះបណ្តាលភាសាអង់គ្លេស
- ចុះបញ្ជិកាកិច្ចសន្យាសេវារកការងារឱ្យធ្វើ នៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- មានកិច្ចសន្យាការងារជាមួយនិយោជក
- មានប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស **(OCWC)** (១ ថ្ងៃ)
- មានលិខិតឆ្លងដែន **(Passport)**
- មានលិខិតអនុញ្ញាតជាគោលការណ៍ **(In Principle Approval)** (៧ ថ្ងៃ)
- ទទួលបានការណែនាំតម្រង់ទិសមុនចេញដំណើរ (១ ថ្ងៃ)

## 4 មុនពេលបំពេញការងារ ( ៤៨ ថ្ងៃ )

- ទទួលបានការបណ្តុះបណ្តាលស្តីពីច្បាប់ ទំនៀមទម្លាប់រស់នៅ លក្ខខណ្ឌការងារ និងការស្វែងរកអន្តរាគមន៍ពេលមានបញ្ហា នៅក្រសួងការងារសិង្ហបុរី (វិញ្ញាបនបត្រ) (៣ ថ្ងៃ)
- មានបណ្ណការងារ **(Work Permit)** (៤៥ ថ្ងៃ)
- មានធានារ៉ាប់រង
- ចូលធ្វើការស្របតាមកិច្ចសន្យាការងារ

## 5 អំឡុងពេលបំពេញការងារ

- អនុវត្តទៅតាមកិច្ចព្រមព្រៀង និងលក្ខខណ្ឌការងារជាមួយនិយោជកសិង្ហបុរី ដូចបានកំណត់ក្នុង "កិច្ចសន្យាការងារ"

## 6 ការធ្វើមាតុភូមិនិវត្តន៍

- ទូទាត់អត្ថប្រយោជន៍ផ្សេងៗ(បើមាន)
- ទីភ្នាក់ងារសិង្ហបុរី ត្រូវជូនដំណឹងទៅអាជ្ញាធរមូលដ្ឋាន មុនពេលពលករវិលត្រឡប់ មកប្រទេសកម្ពុជាវិញ
- ទីភ្នាក់ងារជ្រើសរើសឯកជនត្រូវរាយការណ៍អំពីការវិលត្រឡប់របស់ពលករ មកក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**ដំណើរការឯកសារមានរយៈពេលប្រមាណ ៥៩ ថ្ងៃ (ឯកសារគ្រប់គ្រាន់ និងត្រឹមត្រូវ)**


ករណីមានចម្ងល់ សូមទំនាក់ទំនងប្រព័ន្ធ
**Hotline លេខ 1297 ឬ 1286**
https://www.facebook.com/mlvt.gov.kh
សម្រាប់ ពលករទេសន្តរប្រវេសន៍ : https://t.me/KhmerMigrantWorker

ស្ថានឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសសិង្ហបុរី៖
The Royal Embassy of Cambodia to the Republic of Singapore
+65 6341 9785

# នីតិវិធី នៅធ្វើការនៅប្រទេសថៃដោយស្របច្បាប់

ដើម្បីទៅធ្វើការងារ នៅប្រទេសថៃដោយស្របច្បាប់ ពលករត្រូវអនុវត្តតាមនីតិវិធី ដូចខាងក្រោម៖

## 1 ការចុះឈ្មោះស្វែងរកការងារ ( ១ ថ្ងៃ )

- អាយុចាប់ពី ១៨ ឆ្នាំឡើង
- ប្រវត្តិរូបសង្ខេប
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- សំបុត្រកំណើត
- សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ
- រូបថត ៤ x ៦ (ផ្ទៃស)

## 2 ការសម្ភាស និងចុះកិច្ចសន្យា ( ១ ថ្ងៃ )

- សម្ភាសជាមួយទីភ្នាក់ងារជ្រើសរើសឯកជន
- ធ្វើកិច្ចសន្យាសេវារកការងារឱ្យធ្វើ ជាមួយទីភ្នាក់ងារជ្រើសរើសឯកជន
- ទទួលបានការណែនាំអំពីកិច្ចសន្យាការងារស្តង់ដា រវាងពលករ និងនិយោជកថៃ ដោយទីភ្នាក់ងារជ្រើសរើសឯកជន

## 3 មុនពេលចេញដំណើរ ( ៣៧ ថ្ងៃ )

- ចុះបញ្ជិកាកិច្ចសន្យាសេវារកការងារឱ្យធ្វើ នៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- មានកិច្ចសន្យាការងារជាមួយនិយោជកថៃ
- មានប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស **(OCWC)** (១ ថ្ងៃ)
- មានលិខិតឆ្លងដែន **(Passport)** ឬលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស **(TD)** (២ ថ្ងៃ)
- មានលិខិតអនុញ្ញាតឱ្យប្រើប្រាស់កម្លាំងពលកម្មបរទេស **(Demand Letter)** ចេញដោយក្រសួងការងារថៃ (៦ ថ្ងៃ)
- មានបញ្ជីឈ្មោះពលករកម្ពុជា **(Cambodian Name List)** ចេញដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (១ ថ្ងៃ)
- ដំណើរការរៀបចំបណ្ណអនុញ្ញាតការងារ **(Work Permit)** (២១ ថ្ងៃ)
- មានទិដ្ឋាការការងារចេញដោយស្ថានទូតថៃប្រចាំកម្ពុជា (៥ ថ្ងៃ)
- ទទួលបានការណែនាំតម្រង់ទិសមុនចេញដំណើរ (១ ថ្ងៃ)

## 4 មុនពេលបំពេញការងារ ( ២ ថ្ងៃ )

- ទទួលបានការណែនាំតម្រង់ទិសមុនចូលធ្វើការ ពេលទៅដល់ប្រទេសថៃ ដោយរាជរដ្ឋាភិបាលថៃ នៅមជ្ឈមណ្ឌលណែនាំតម្រង់ទិសក្រោយពេលទៅដល់ និងសមាហរណកម្ម ដើម្បីយល់ដឹងអំពីលក្ខខណ្ឌការងារ ទំនៀមទម្លាប់រស់នៅ និងការស្វែងរកការអន្តរាគមន៍ពេលមានបញ្ហា
- ពិនិត្យសុខភាពពេលទៅដល់ប្រទេសថៃ
- មានធានារ៉ាប់រងការងារ
- មានបណ្ណអនុញ្ញាតការងារ **(Work Permit)**
- ចូលធ្វើការស្របតាមកិច្ចសន្យាការងារ

## 5 អំឡុងពេលបំពេញការងារ

- អនុវត្តទៅតាមកិច្ចព្រមព្រៀង និងលក្ខខណ្ឌការងារជាមួយនិយោជកថៃ ដូចបានកំណត់ក្នុង "កិច្ចសន្យាការងារ"

## 6 ការធ្វើមាតុភូមិនិវត្តន៍

- និយោជកត្រូវជូនដំណឹងទៅអាជ្ញាធរមូលដ្ឋាន មុនពេលពលករវិលត្រឡប់មកប្រទេសកម្ពុជាវិញ
- និយោជកត្រូវចេញលិខិតបញ្ជាក់ការងារជូនពលករ
- ទីភ្នាក់ងារជ្រើសរើសឯកជនត្រូវធ្វើរបាយការណ៍ អំពីការវិលត្រឡប់ របស់ពលករមកក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ស្នើសុំទូទាត់ប្រាក់បំណាច់ និងអត្ថប្រយោជន៍ផ្សេងៗ

ដំណើរការឯកសារមានរយៈពេល ៤១ ថ្ងៃ សម្រាប់ពលករប្រើប្រាស់លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស **(TD)**
និងរយៈពេល ៥៤ ថ្ងៃ សម្រាប់ពលករប្រើប្រាស់លិខិតឆ្លងដែន **(Passport)**

ករណីមានចម្ងល់ សូមទំនាក់ទំនងប្រព័ន្ធ
**Hotline លេខ 1297 ឬ 1286**
https://www.facebook.com/mlvt.gov.kh
សម្រាប់ ពលករទេសន្តរប្រវេសន៍https://t.me/KhmerMigrantWorker

អនុព័ន្ធការងារអមស្ថានទូតកម្ពុជា
ប្រចាំប្រទេសថៃ
https://www.facebook.com/la.in.thailand
+66 (0) 94 092 5905 , +66 (0) 94 416 5518

# នីតិវិធី នៅធ្វើការនៅប្រទេសជប៉ុន ដោយស្របច្បាប់

ដើម្បីទៅធ្វើការនៅប្រទេសជប៉ុនដោយស្របច្បាប់ កម្មសិក្សាការី-ពលករជំនាញ ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោមៈ

## 1 ការចុះឈ្មោះស្វែងរកការងារ ( ១ ថ្ងៃ )

- អាយុចាប់ពី ១៨ ឆ្នាំឡើង
- ប្រវត្តិរូបសង្ខេប
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- សំបុត្រកំណើត
- សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ
- រូបថត ៤ x ៦ (ផ្ទៃស)

## 2 ការសម្ភាស និងចុះកិច្ចសន្យា ( ១ ថ្ងៃ )

- សម្ភាសជាមួយនិយោជកជប៉ុន ឬសមាគមគ្រប់គ្រង
- ចុះកិច្ចសន្យាសេវារកការងារឱ្យធ្វើជាមួយទីភ្នាក់ងារជ្រើសរើសឯកជន

## 3 មុនពេលចេញដំណើរ ( ៩៥ ថ្ងៃ )

- ទទួលបានការបណ្តុះបណ្តាលភាសាជប៉ុន និងជំនាញ
- ចុះបញ្ជិកាកិច្ចសន្យាសេវារកការងារឱ្យធ្វើនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- មានកិច្ចសន្យាការងារជាមួយនិយោជក
- មានប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស **(OCWC)** (១ ថ្ងៃ)
- មានលិខិតឆ្លងដែន **(Passport)**
- មានលិខិតអនុសាសន៍ ឬលិខិតបញ្ជាក់ (២ ថ្ងៃ)
- មានលិខិតអនុញ្ញាតការងារ **(COE)** (៩០ ថ្ងៃ)
- មានទិដ្ឋាការការងារដែលចេញដោយស្ថានទូតជប៉ុនប្រចាំនៅកម្ពុជា (១ ថ្ងៃ)
- ទទួលបានការណែនាំតម្រង់ទិសមុនចេញដំណើរ (១ ថ្ងៃ)

## 4 មុនពេលបំពេញការងារ ( ៣០ ថ្ងៃ )

- ទទួលបានការបណ្តុះបណ្តាលស្តីពីច្បាប់ ទំនៀមទម្លាប់រស់នៅ ភាសាជប៉ុន និងការស្វែងរកអន្តរាគមន៍ពេលមានបញ្ហា នៅមជ្ឈមណ្ឌលនៃសមាគមគ្រប់គ្រង (៣០ ថ្ងៃ)
- មានបណ្ណអនុញ្ញាតស្នាក់នៅ
- មានធានារ៉ាប់រង
- ចូលធ្វើការស្របតាមកិច្ចសន្យាការងារ

## 5 អំឡុងពេលបំពេញការងារ

- អនុវត្តទៅតាមកិច្ចព្រមព្រៀង និងលក្ខខណ្ឌការងារជាមួយនិយោជកជប៉ុន ដូចបានកំណត់ក្នុង “កិច្ចសន្យាការងារ”

## 6 ការធ្វើមាតុភូមិនិវត្តន៍

- ទទួលលិខិតបញ្ជាក់ការងារពីនិយោជក
- ទូទាត់ប្រាក់សោធននិវត្តន៍ និងអត្ថប្រយោជន៍ផ្សេងៗ
- សមាគមគ្រប់គ្រងត្រូវជូនដំណឹងទៅអាជ្ញាធរមូលដ្ឋានមុនពេលកម្មសិក្សាការី-ពលករជំនាញ វិលត្រឡប់មកប្រទេសកម្ពុជាវិញ
- ទីភ្នាក់ងារជ្រើសរើសឯកជន ត្រូវរាយការណ៍អំពីការវិលត្រឡប់របស់កម្មសិក្សាការី-ពលករជំនាញ មកក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ដំណើរការឯកសារមានរយៈពេលប្រមាណ ១២៧ ថ្ងៃ (ឯកសារគ្រប់គ្រាន់ និងត្រឹមត្រូវ)

ករណីមានចម្ងល់ សូមទំនាក់ទំនងប្រព័ន្ធ
**Hotline លេខ 1297 ឬ 1286**
**https://www.facebook.com/mlvt.gov.kh**
សម្រាប់ ពលករទេសន្តរប្រវេសន៍ : **https://t.me/KhmerMigrantWorker**

ស្ថានឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសជប៉ុន
អនុព័ន្ធការងារអមស្ថានទូតកម្ពុជាប្រចាំប្រទេសជប៉ុន - Labour Attaché
**08033626168**

# នីតិវិធី នៅធ្វើការនៅតំបន់រដ្ឋបាលពិសេសហុងកុងដោយស្របច្បាប់

ដើម្បីទៅធ្វើការងារ
នៅតំបន់រដ្ឋបាលពិសេសហុងកុង
ដោយស្របច្បាប់ ពលករត្រូវអនុវត្ត
តាមនីតិវិធីដូចខាងក្រោម៖




## 1 ការចុះឈ្មោះស្វែងរកការងារ ( ១ ថ្ងៃ )

- អាយុចាប់ពី ១៨ឆ្នាំ ដល់ ៤៥ឆ្នាំ
- ភេទស្រី
- ប្រវត្តិរូបសង្ខេប
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- សំបុត្រកំណើត
- សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ
- រូបថត ៤ x ៦ (ផ្ទៃស)



## 2 ការសម្ភាស និងចុះកិច្ចសន្យា ( ១ ថ្ងៃ )

- សម្ភាសជាមួយនិយោជកហុងកុង
- ចុះកិច្ចសន្យាសេវារកការងារឱ្យធ្វើ
ជាមួយទីភ្នាក់ងារជ្រើសរើសឯកជន




## 3 មុនពេលចេញដំណើរ ( ៤៧ ថ្ងៃ )

- ទទួលបានការបណ្តុះបណ្តាលភាសាអង់គ្លេស
- ចុះបញ្ជិកាកិច្ចសន្យាសេវារកការងារឱ្យធ្វើ
នៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- មានកិច្ចសន្យាការងារជាមួយនិយោជក
- មានប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស **(OCWC)** (១ ថ្ងៃ)
- មានលិខិតឆ្លងដែន **(Passport)**
- មានទិដ្ឋាការចូល (**Entry Visa/Permit**) (៤៥ ថ្ងៃ)
- ទទួលបានការណែនាំតម្រង់ទិសមុនចេញដំណើរ (១ ថ្ងៃ)



## 4 មុនពេលបំពេញការងារ ( ២ ថ្ងៃ )

- ទទួលបានការបណ្តុះបណ្តាលស្តីពីច្បាប់
ទំនៀមទម្លាប់រស់នៅ លក្ខខណ្ឌការងារ និងការស្វែងរក
អន្តរាគមន៍ពេលមានបញ្ហា នៅសមាគមហុងកុងដើម្បី
អភិវឌ្ឍធនធានមនុស្សកម្ពុជា (**HKCAMHR**) (២ ថ្ងៃ)
- មានធានារ៉ាប់រង
- ចូលធ្វើការស្របតាមកិច្ចសន្យាការងារ



## 5 អំឡុងពេលបំពេញការងារ

- អនុវត្តទៅតាមកិច្ចព្រមព្រៀង និងលក្ខខណ្ឌការងារជាមួយ
និយោជកហុងកុង  ដូចបានកំណត់ក្នុង "កិច្ចសន្យាការងារ"

## 6 ការធ្វើមាតុភូមិនិវត្តន៍

- ទូទាត់អត្ថប្រយោជន៍ផ្សេងៗ(បើមាន)
- ទីភ្នាក់ងារមុខរបរហុងកុង ត្រូវជូនដំណឹងទៅ
អាជ្ញាធរមូលដ្ឋានមុនពេល ពលករវិលត្រឡប់
មកប្រទេសកម្ពុជាវិញ
- ទីភ្នាក់ងារជ្រើសរើសឯកជនត្រូវរាយការណ៍អំពី
ការវិលត្រឡប់របស់ពលករ មកក្រសួងការងារ
និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ដំណើរការឯកសារមានរយៈពេលប្រមាណ
៥១ ថ្ងៃ (ឯកសារគ្រប់គ្រាន់ និងត្រឹមត្រូវ)

ករណីមានចម្ងល់ សូមទំនាក់ទំនងប្រព័ន្ធ
**Hotline លេខ 1297 ឬ 1286**
**https://www.facebook.com/mlvt.gov.kh**
សម្រាប់ ពលករទេសន្តរប្រវេសន៍ : **https://t.me/KhmerMigrantWorker**

ស្ថានឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជា
ប្រចាំតំបន់រដ្ឋបាលពិសេសហុងកុង៖
Consulate General of the Kingdom of Cambodia in Hong Kong
**+852 2546 0718**